**SPRING PARKS PRIMARY SCHOOL**
*Learning and Growing - Safety - Together*

**West Campus - Administration**
24 Erica Street, Springvale 3171 ☎ 9546 6402

**Valley Campus**
27-39 Clarke Road, Springvale South 3172 ☎ 9547 3222
✉ spring.parks.ps@education.vic.gov.au springparksps.vic.edu.au





ជំរាបមាតាបិតា/អាណាព្យាបាល,

## គិលានុបដ្ឋាយិការសលា

សិស្សានុសិស្សទាំងឡាយ បានទទួលស្រោមសំបុត្រដ៏ធំមួយជាមួយនឹងកម្រងសំណួរពីគិលលានុបដ្ឋាយិការសាលាយើងនៅខាងក្នុង។ កម្មវិធីគិលានុបដ្ឋាយិការសាលាបឋមសិក្សាផ្តល់ឱកាសឲ្យមាតាបិតា,គ្រូបង្រៀននិងគិលានុបដ្ឋាយិការដើម្បីធ្វើការរួមគ្នាលើកកំពស់សុខភាពនិងសុខមាលភាពដល់កុមារក្នុងសាលា។ មានបណ្ណចម្លើយខ្លះបានផ្ញើមកវិញហើយ,តែនៅមានកម្រងសំណួរមួយចំនួនមិនទាន់ផ្ញើមកវិញ។ ប្រសិនជាលោកអ្នកប្រាថ្នាឲ្យកូនចៅរបស់ខ្លួនចូលរួមក្នុងកម្មវិធីនេះ,សូមបំពេញបណ្ណហើយគូសថាបាទ/ចាស (yes) ក្នុងប្រអប់៨ជ្រុងជាតំណាងនៃការយល់ព្រម,បើពុំនោះសោត,សូមគូសក្នុងប្រអប់ no ហើយចុះហត្ថលេខា។ ប្រសិនជាលោកអ្នកបានធ្វើបាត់បណ្ណសំណួរ,សូមទាក់ទងនឹងការិយាល័យដើម្បីយកបណ្ណសំណួរថ្មី។គិលានុបដ្ឋាយិការនឹងប្រមូលយកកម្រងសំណួរពីគ្រូប្រចាំថ្នាក់។

### កំណត់ប្រចាំថ្ងៃ 12/6/2023

១២/៦: បុណ្យខួបកំណើតព្រះមហាក្សត្រ:សំរាក១ថ្ងៃ
១៣/៦: កម្មវិធីឆ្មែស្និទ្ធស្នាល:សាខាវ៉ាល្លី
១៦/៦: គោរពទង់ជាតិចាត់ចែងដោយថ្នាក់ទី 5/6A ,1/2L ,3/4M
១៩/៦: ក្រុមប្រឹក្សាប្រជុំនៅម៉ោង៦ល្ងាចតាមwebex
២០/៦: ថ្ងៃសម្ភាសន៏នៃថ្នាក់ Mrs Otenstein: Valley។
២១/៦: របាយការណ៏សិស្សផ្សាយនៅលើក្លោងទ្វរពត៏មាន
២៣/៦: គោរពទង់ជាតិនៃសាលាទាំងមូល:
នៅសាខាវ៉ាល្លី:ម៉ោង៩:៣០ព្រឹក
១០/៧: ត្រីមាសទី៣ចាប់ផ្តើមនៅម៉ោង៨:៥០ព្រឹក
១២/៧:កិច្ចសម្ភាសន៏រវាងមាតាបិតា/គ្រូ:ម៉ោង២:៣០-៧:០០
១៤/៧: អបអរសាទរ១០០ថ្ងៃសិក្សានៅសាលា: សាខាវ៉ាល្លី
គោរពទង់ជាតិនៅម៉ោង៣:០០ល្ងាច

### កិច្ចសម្ភាសន៏រវាងមាតាបិតានិងគ្រូ:

គ្រួសារទាំងឡាយនឹងទទួលបណ្ណបញ្ជាក់ម៉ោងមកជួបសមម្ភាសន៏នៅសប្តាហ៏នេះ។ អ្នកបកប្រែក៏បានចាត់ចែងជូន(បើបានបញ្ជាក់ថាត្រូវការ), ហើយគ្រូក៏បានប្រុងប្រៀបជាស្រេចដើម្បីជួបមាតាបិតា។ សូមឆែកមើលពេលម៉ោងឲ្យបានច្បាស់លាស់ហើយអញ្ជើញមកឲ្យទាន់ពេល, បើពុំដូច្នោះទេ,ពេលសម្ភាសន៏ច្បាស់ជាលើកទៅថ្ងៃក្រោយ។ កុមារនឹងមករៀនជាធម្មតាក្នុងថ្ងៃពុធនេះ,ព្រោះយើងខ្ញុំមានគ្រូបច្ចេកទេសដទៃមកបង្រៀនកុមារក្នុងថ្ងៃនេះ។កុមារនឹងចេញទៅផ្ទះនៅម៉ោង៣:៣០ដូចសព្វដង។ នៅសាខាខាងលិច,កុមារនឹងចេញទៅផ្ទះតាមរយៈបន្ទប់ធំ,នៅសាខាវ៉ាល្លីតាមរយៈអគ្គាLEC។របាយការណ៏នៃថ្នាក់Mrs Otenstein នឹងអាចមើលតាមរយៈក្លោងទ្វារពត៍មាននៅថ្ងៃច័ន្ទទី១៩/៦, ហើយសំរាប់ថ្នាក់ទាំងឡាយនៅថ្ងៃពុធទី ២១/៦។

### បណ្ណពត៍មានប្រចាំថ្នាក់:

បណ្ណពត៍មានប្រចាំថ្នាក់នៃត្រីមាសទី៣នឹងផ្ញើជូនទៅផ្ទះជាមួយកុមារនៅថ្ងៃច័ន្ទទី១០/៧។សូមឆែកមើលក្នុងកាបូបរបស់កុមារព្រោះក្នុងបណ្ណនេះមានពត៍មានដ៏សំខាន់អំពីអ្វីៗដែលគ្រូបានបង្រៀនឲ្យកុមារក្នុងថ្នាក់ហើយនឹងថ្ងៃសំខាន់ៗសំរាប់កុមារ។

### សិស្សប្រចាំត្រីមាស:

គ្រូៗនឹងប្រគល់មេដាយ "សិស្សប្រចាំត្រីមាស "ប្រចាំថ្នាក់របស់ខ្លួននៅពេលគោរពទង់ជាតិនាថ្ងៃសុក្រទី២៣/៦/២០២៣នៅសាខាវ៉ាល្លី។ មាតាបិតានៃកុមារដែលនឹងទទួលមេដាយនឹងបានទទួលសំបុត្រអញ្ជើញមុន១សប្តាហ៏ដើម្បីមករួមក្នុង ពេលគោរពទង់ជាតិវេលាម៉ោង៩:៣០ព្រឹកក្នុងថ្ងៃនេះ។
សាលានឹងបញ្ចប់ត្រីមាសទី២នៅ ម៉ោង២:៣០។

ត្រីមាសទី៣ចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី១០/៧វេលាម៉ោង៨:៥០ព្រឹក។

Julie Fisher :

នាយកសាលា

សាលាយើងមានក្តីសោមនស្សជាគូរភាគីនឹង :**Food Bank,Ardoch,Woodleigh School, OSH Club,Berry Street,Ed Connect**

## វិស្សមកាលសំរាប់បុគ្គលិធ្វើការយូរឆ្នាំ:

Mrs Otenstein នឹងសំរាកក្នុងរយ:ពេលនៃត្រីមាសទី៣ទាំងមូលសំរាប់វិស្សមកាលដោយបានបំរើក្នុងវិស័យអប់រំបានយូរឆ្នាំ។Mrs Edmondson នឹងមកបង្រៀនជំនួសនៅ៥សប្តាហ៏ដំបូង,បន្ទាប់មក Mrs Dounis នឹងមកជំនួសនៅ៥សប្តាហ៏ចុងក្រោយ។ម្តងទៀត,សាលាយើងសំណាងណាស់ដោយបានគ្រូដ៏មានការពិសោធន៏ដ៏ពេញបរិបូណ៌មកធ្វើការនៅសាលាយើង។ថ្នាក់Mrs Otenstein នឹងធ្វើសម្ភាសន៏នៅថ្ងៃអង្គារទី២០/៦។កិច្ចសម្ភាសន៏មុនម៉ោង៣:៣០ល្ងាចនឹងប្រព្រឹត្តទ្បើងនៅក្នុងបន្ទប់នាយកសាលា,ក្រោយម៉ោង៣:៣០,នៅបន្ទប់របស់អ្នកគ្រូ។

## STOMP: កម្មវិធីរៀនរាំ

STOMP នឹងត្រទ្បប់មកសាលាយើងវិញនៅត្រីមាសទី៣។ កុមារនឹង រៀនជាមួយនឹងក្រុមបង្រៀនរាំមកពី STOMP. ដែលនឹងចាប់ផ្តើមនៅ ថ្ងៃទី២៨ ខែកក្កដានៅសាខាខាងលិច,ហើយសាខាវ៉ាល្លីនឹងចាប់ផ្តើម នៅទី២៥ ខែ កក្កដា។។

កុមារនឹងរៀនរាំរៀងរាល់សប្តាហ៏រហូតដល់ថ្ងៃសិល្ប:សាលាដែលនឹងប្រព្រឹត្តិទ្បើងនៅថ្ងៃព្រហស្បត៏ទី១៨ ខែកញ្ញា នៅរោងមហាសាលសាលាក្រុងស្ព្រីងវ៉េល(Springvale Town Hall )។

ក្នុងថ្ងៃនេះ,សាលាទាំងមូលនឹងធ្វើដំណើរដោយទ្បានក្រុងទៅ Springvale Town Hall ដើម្បីធ្វើការហាត់សមជាទីបញ្ចប់សំរាប់រាត្រីសិល្ប:នៅយប់នេះ។

កុមារនឹងបរិភោគបាយថ្ងៃត្រង់នៅទីនេះ, ហើយចាកចេញពីសាលានៅម៉ោង៩:៣០ព្រឹក,ត្រទ្បប់មកវិញនៅម៉ោង៣:០០ល្ងាច។

## ព្រឹត្តិការប្រណាំងរត់ចម្ងាយ:

កាលពីថ្ងៃសុក្រទី២/៦,សាលាយើងមានតំណាងសិស្ស៣នាក់ទៅរួមប្រកួតរត់ចម្ងាយនៅ Tatterson Park ។

កុមារបានជាប់លេខក្នុង ចំណោមកីទ្បាករទាំង៨ពូកែជាងគេ។ ហើយនេ:ជាសមិទ្ធផលមួយដ៏គួរឲ្យចាប់អារម្មណ៏។

ខាងក្រោមនេ:ជានាមនិងចំណាត់ថ្នាក់នៃកុមារដទៃនៃសាលាយើង

Japneet: 20th; Anton: 22nd & Ben: 22nd..

សូមសរសើរដល់កុមារទាំងទ្បាយហើយនឹងគ្រួសារដែលបានគាំទ្រឲ្យកុមារចូលរួមក្នុងព្រឹត្តិការណ៏នេ:។

## ថ្នាក់ទី១/២ទៅសួនការពារសត្វ Healesville Sanctury



















## ប្រធានបទនៃកិច្ចប្រជុំលើអ៊ិនធើណែតជាបន្ទាប់គឺ

''លេងហ្គេមលើអ៊ិនធើណែតនិងគ្រួសាររបស់អ្នក ''។
ថ្ងៃពុធទី២៦/៧-វេលាម៉ោង៧:៣០យប់ .




## ថ្ងៃអេស្ប៉ាញ៉ុល

















ACHIEVEMENT





